## បញ្ជីពិនិត្យការត្រៀមលក្ខណៈសម្រាប់គ្រាអាសន្ន

- [ ] រក្សាឯកសារច្បាប់ដើមទាំងអស់នៅកន្លែងមានសុវត្ថិភាពណាមួយ
- [ ] បំពេញទម្រង់បែបបទសម្រាប់សមាជិកគ្រួសារគ្រប់គ្នា
- [ ] ចែករំលែកច្បាប់ចម្លងជាមួយអ្នកណាម្នាក់ដែលអាចទុកចិត្តបាន និងគ្រូបង្រៀនកូនៗអ្នក
- [ ] ចុះហត្ថលេខា (និងធ្វើការបញ្ជាក់ពីសារការី ប្រសិនបើចាំបាច់) នូវរាល់ទម្រង់ផ្លូវច្បាប់ទាំងអស់ (ទម្រង់ផ្ទេរសិទ្ធិអាណាព្យាបាលអចិន្ត្រៃ ឬទម្រង់ផ្ទេរសិទ្ធិអាណាព្យាបាលបណ្តោះអាសន្ន)
- [ ] ដាក់ជាប់ខ្លួននូវបញ្ជីរាយនាមអង្គការនានាដែលមានសារៈប្រយោជន៍




## តំណភ្ជាប់ទៅកាន់ទម្រង់បែបបទផ្សេងៗ

**ទម្រង់បែបបទទាំងអស់៖** bit.ly/AAF-familyprep
- រួមទាំងទម្រង់ព័ត៌មានគ្រាអាសន្នសម្រាប់អ្នកផ្ទាល់ និងទម្រប់ព័ត៌មានគ្រាអាសន្នសម្រាប់កូនរបស់អ្នក
- **ទម្រង់ផ្ទេរសិទ្ធិអាណាព្យាបាលអចិន្ត្រៃ៖** bit.ly/standby-guardianship
- **ទម្រង់ផ្ទេរសិទ្ធិអាណាព្យាបាលបណ្តោះអាសន្ន៖** bit.ly/parental-designation

*Note: Information adapted from New York Immigration Coalition.*

## បញ្ជីអង្គការនានាដែលមានសារៈប្រយោជន៍ និងព័ត៌មានផ្នែកច្បាប់នៅ NYC

ខ្លឹមសារនេះត្រូវបានផ្តល់ជូនសម្រាប់គោលបំណងអប់រំទូទៅតែប៉ុណ្ណោះ ហើយមិនមានគោលបំណងជាដំបូន្មានផ្នែកច្បាប់ទេ។ ពិគ្រោះជាមួយអ្នកជំនាញផ្នែកច្បាប់ដែលមានសមត្ថភាព ដើម្បីពិភាក្សាលម្អិតអំពីករណីរបស់អ្នក។

**Arab American Association of New York**
(718) 745-3523 | arabamericanny.org

**Asian Americans for Equality**
(212) 979-8381 | aafe.org

**Brooklyn Chinese-American Association**
(718) 765-1110 | bca.net/eng/home.html

**Chinese-American Planning Council**
(212) 941-0920 | cpc-nyc.org

**Council of Peoples Organization**
(718) 434-3266 | copo.org

**Damayan Migrant Workers**
(212) 564-6057 | damayanmigrants.org

**Hamilton-Madison House**
(212) 349-3724 | hamiltonmadisonhouse.org

**Homecrest Community Services**
(718) 376-4036 | homecrest.org

**Korean American Family Service Center**
(718) 460-3800 (24-Hour Hotline) | kafsc.org

**Korean Community Services of Metropolitan New York**
(718) 939-6137 | kcsny.org

**Mekong NYC**
(347) 918-9220 | mekongnyc.org

**Sapna NYC**
(718) 828-9772 | sapnanyc.org

**South Asian Council for Social Services**
(718) 321-7929 | sacssny.org

ឯកសារណែនាំនេះមានបកប្រែជាភាសាបេងហ្គាល់ ភាសាចិន និងភាសាអាស៊ីផ្សេងៗទៀត។ សូមសាកសួរមជ្ឈមណ្ឌលសហគមន៍ ប្រសិនបើត្រូវការឯកសារបកប្រែ ឬចូលទាញយកនៅទីនេះ។ bit.ly/AAF-familyprep

Asian American Federation

# ជំហានទាំង ៥ សម្រាប់ជនអន្តោប្រវេសន៍ ក្នុងការការពារគ្រួសារអ្នកក្នុងគ្រាអាសន្ន

ការវាយឆ្មក់បង្ក្រាបបទល្មើសអន្តោប្រវេសន៍ ឬគ្រោះអាសន្ននានាអាចកើតឡើងភ្លាមៗដោយមិនបានដឹងជាមុន។ ចូរត្រៀមខ្លួនដើម្បីផ្តល់សុខសុវត្ថិភាព និងថែរក្សាកូនៗជាទីស្រឡាញ់របស់អ្នក ប្រសិនបើបែកគ្នាដោយប្រការណាមួយ។ សេចក្តីណែនាំនេះនឹងជួយអ្នករៀបចំតាមជំហាន និងទម្រង់បែបសាមញ្ញងាយស្រួល។



© 2025 Asian American Federation. All rights reserved.



## ចាប់ផ្ដើមនៅទីនេះ

## 1 ប្រមូលទុកនូវឯកសារសំខាន់ៗ

- [ ] ច្បាប់ចម្លងលិខិតឆ្លងដែន បណ្ណការងារកាតបៃតង ឬអត្តសញ្ញាណបណ្ណចេញដោយរដ្ឋ
- [ ] បណ្ណសន្តិសុខសង្គម ឬ លេខអត្តសញ្ញាណកម្មសារពើពន្ធ
- [ ] សំបុត្រកំណើត/លិខិតឆ្លងដែនសម្រាប់សមាជិកគ្រួសារទាំងអស់ រួមទាំងកូនៗអ្នក
- [ ] បណ្ណធានារ៉ាប់រងសុខភាព និងកំណត់ត្រាសុខភាពផ្សេងៗ
- [ ] បញ្ជីទំនាក់ទំនងក្នុងគ្រាអាសន្ន
- [ ] ឯកសារផ្លូវច្បាប់ (ដីកាតុលាការ ដីកាហាមឃាត់ សំបុត្រអាពាហ៍ពិពាហ៍)
- [ ] ឯកសារបញ្ជាក់អាសយដ្ឋាន (លិខិតជួល, វិក័យប័ត្រទឹកភ្លើង វិក័យប័ត្រហ្គាស់ វិក័យប័ត្រសម្រាម, របាយការណ៍ធនាគារ)
- [ ] លិខិតចុះឈ្មោះចូលរៀន ឬឯកសារបញ្ជាក់ការងារ




## 2 បំពេញទម្រង់ព័ត៌មានសម្រាប់គ្រាអាសន្ន

- សម្រាប់ខ្លួនអ្នក៖ បំពេញទម្រង់ព័ត៌មានសម្រាប់គ្រាអាសន្ន ដែលគ្រួសាររបស់អ្នកអាចត្រូវការចាំបាច់ ប្រសិនបើអ្នកត្រូវបានចាប់ខ្លួន ឬឃុំឃាំង។
- សម្រាប់កូនអ្នក៖ បំពេញទម្រង់ព័ត៌មានសម្រាប់គ្រាអាសន្ន ដែលអ្នកមើលថែកូនរបស់អ្នក អាចត្រូវការប្រើប្រាស់។ ប្រសិនបើអ្នកមានកូនច្រើនជាងមួយ សូមបំពេញទម្រង់ដាច់ដោយឡែកពីគ្នាសម្រាប់កូននីមួយៗ។
- រក្សាទម្រង់ទាំងនេះនៅក្នុងកញ្ចប់ឯកសាររបស់អ្នក។ មិនត្រូវការមានសាក្សី ឬសេចក្ដីបញ្ជាក់ពីសារការីទេ។

សូមស្វែងរកតំណភ្ជាប់ទៅកាន់ទម្រង់បែបបទនានា នៅខាងក្រោមបញ្ជីពិនិត្យការត្រៀមលក្ខណៈសម្រាប់គ្រាអាសន្នa

## 3 សម្របសម្រួល និងទាក់ទងទៅកាន់សាលារៀនរបស់កូនអ្នក

- [ ] ធ្វើបច្ចុប្បន្នភាពនូវរាល់បណ្ណទំនាក់ទំនងគ្រាអាសន្ន (ពណ៌ខៀវ) របស់សាលា និងគណនីសាលា NYC របស់កូនអ្នក រួមមានឈ្មោះពេលលេញរបស់បុគ្គលបីរូបបន្ថែមទៀត ដែលអាចទាក់ទងទៅបានក្នុងករណីមានអាសន្ន។
- [ ] ធ្វើបច្ចុប្បន្នភាពឈ្មោះរបស់អ្នកដែលអាចមិនមានសិទ្ធិបីបាច់កូនអ្នកហើយផ្ញើច្បាប់ចម្លងនៃ អាជ្ញាការពារទៅសាលារៀនរបស់កូនអ្នក
- [ ] ធ្វើបច្ចុប្បន្នភាពព័ត៌មានសុខភាពរបស់កូនអ្នក
- [ ] រាយនាមបងប្អូន របស់កូនអ្នកទាំងអស់






## 4 សម្រេចចិត្តជ្រើសរើសអ្នកថែរក្សាបីបាច់កូនអ្នកទុកជាមុន

**ទម្រង់ផ្ទេរសិទ្ធិអាណាព្យាបាលបណ្ដោះអាសន្ន (រយៈពេលខ្លី) ឬ ទម្រង់ផ្ទេរសិទ្ធិអាណាព្យាបាលអចិន្ត្រៃ (ផ្ទេរសិទ្ធិពេញលេញ)**

- មានជម្រើសពីរផ្សេងគ្នាសម្រាប់ឪពុកម្ដាយក្នុងការអនុញ្ញាតឱ្យបុគ្គលណាម្នាក់ទៀតធ្វើការសម្រេចចិត្តសម្រាប់កូនៗក្នុងគ្រាអាសន្ន
- ឪពុកម្ដាយទាំងពីរនាក់ រក្សាសិទ្ធិឪពុកម្ដាយ
- ឪពុកម្ដាយទាំងពីរនាក់ អាចលុបចោលសិទ្ធិអំណាចនៅពេលណាក៏បាន
- អានជម្រើសទាំងពីរ បន្ទាប់មកជ្រើសរើសជម្រើសដ៏ល្អបំផុតសម្រាប់អ្នក។

## 5 រៀនពីរបៀបស្វែងរកបុគ្គលជាទីស្រឡាញ់ណាម្នាក់ដែលជាប់ឃុំឃាំង

- I ប្រើមធ្យោបាយស្វែងរកអ្នកជាប់ឃុំតាមអ៊ីនធឺណិតរបស់ ICE៖ locator.ice.gov/odls/#/search
- សម្រាប់អ្នកដែលមានអាយុលើសពី 18 ឆ្នាំ សូមទូរសព្ទទៅកាន់លេខ (866) 347-2423 ឬស្វែងរកតាមរយៈឈ្មោះ និងប្រទេសកំណើត ឬលេខអត្តសញ្ញាណជនអន្តោប្រវេសន៍